**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

**មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍**
**សើស្បែកនិងកាមរោគ**

# របាយការណ៍ស្តីពី
# សកម្មភាពការអប់រំផ្សព្វផ្សាយ និងធ្វើតេស្តរកមេរោគអេដស៍ និងមេរោគស្វាយថ្ងៃទី៣ ក្នុងព្រឹត្តិការណ៍នៃព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក របស់ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ

**សម្រាប់សកម្មភាពថ្ងៃទី៣៖ ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៤**

ដោយទទួលបានការណែនាំ និងចង្អុលបង្ហាញដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមសាស្ត្រាចារ្យ ឈាង រ៉ា** រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងក្រោមការដឹកនាំដោយផ្ទាល់ដោយ **ឯកឧត្តមវេជ្ជបណ្ឌិត ស៊ឹម ស៊ូយេង** អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល **ឯកឧត្តមវេជ្ជបណ្ឌិត មាន ឈីវុន** ទីប្រឹក្សាក្រសួងសុខាភិបាល និង **លោកសាស្ត្រាចារ្យជំនួយ អ៊ុក វិជ្ជា** ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និង កាមរោគ នារសៀលថ្ងៃសុក្រ ១៥កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៤ ត្រូវនឹងថ្ងៃទី៣ នៃយុទ្ធនាការក្រុមការងារមជ្ឈមណ្ឌលជាតិ និងអង្គការដៃគូពាក់ព័ន្ធបានរៀបចំយុទ្ធនាការផ្សព្វផ្សាយអប់រំការយល់ដឹងស្តីពីការបង្ការមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាមរោគ និងចុះចែកស្រោមអនាម័យដោយឥតគិតថ្លៃដល់កីឡាករអុំទូក និងដល់សាធារណជនដែលចូលរួមនៅក្នុងឱកាសព្រះរាជពិធីបុណ្យអុំទូក បណ្តែត ប្រទីប និងសំពះព្រះខែ អកអំបុក នៅតំបន់ទីក្រុងរណបជ្រោយចង្វារ (OCIC) ដែលនឹងកំពុងបន្តដំណើរការ និងផ្សព្វផ្សាយទាក់ទាញផ្សេងៗ ស្រោមអនាម័យ ព្រមទាំងមានការចូលរួមផងពីសំណាក់ ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក នៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ តំណាងមន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានីភ្នំពេញ អង្គការដៃគូរួមមាន អង្គការ AHF, FHI 360, KHANA, PSI, MHC, CWPD និងសមាគមឈូកស ដើម្បីចូលរួមការពារ ពិនិត្យព្យាបាលសុខភាពជូនប្រជាពលរដ្ឋ ដែលអញ្ជើញមកចូលរួមទស្សនា ក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក និងស្តង់ផ្សព្វផ្សាយអប់រំការយល់ដឹងស្តីពីការបង្ការមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាមរោគរបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ។ ដោយបានត្រៀមនូវសម្ភារ បរិក្ខារ និងខិត្តប័ណ្ណអប់រំផ្សព្វផ្សាយសម្រាប់សកម្មភាពនៃការអប់រំផ្សព្វផ្សាយពីមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាមរោគក្នុងព្រឹត្តិការណ៍នេះនូវស្រោមអនាម័យ ចំនួន ១១៥ ២០០ ស្រោម ទឹករំអិល ចំនួន ៤ ០០០ កញ្ចប់

ខិត្តប័ណ្ណផ្សព្វផ្សាយអំពីការការពារ និងធ្វើតេស្តឈាមចំនួន ៤៥ ៥០០សន្លឹក អាវយឺត ចំនួន ១១៥០ អាវ ថ្នាំបង្ការមុន-ក្រោយពេលប្រឈម (PrEP&PEP) ចំនួន ១០០ឈុត និងតេស្តរកមេរោគអេដស៍ និងកាមរោគ។

## ទីតាំងស្តង់អប់រំផ្សព្វផ្សាយ និងធ្វើតេស្តរកមេរោគអេដស៍នៅតំបន់ទីក្រុងរណបជ្រោយចង្វារ(OCIC)

## សម្រាប់ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៤

➢ **សមាសភាពក្រុមការងារ៖**

- មន្ត្រីមជ្ឈមណ្ឌលជាតិចំនួន ២៥ រូប
- ក្រុមការងារ AHF ០៥ រូប
- ក្រុមការងារ FHI360 ០១ រូប
- ក្រុមការងារ PSI ០៤ រូប
- ក្រុមការងារ KHANA ០៣ រូប
- ក្រុមការងារ MHC ១០ រូប
- ក្រុមការងារ CWPD ០៨ រូប
- ក្រុមការងារ Chhouk Sar ០២ រូប
- ក្រុមការងារកម្មវិធីអេដស៍មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានីភ្នំពេញ ០២ រូប




➢ **សកម្មភាព៖**

សម្រាប់ថ្ងៃទី៣ នៃយុទ្ធនាការអប់រំផ្សព្វផ្សាយស្តីពីមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាមរោគ នៅក្នុងព្រឹត្តិការណ៍នៃព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក វេលាម៉ោង ៨:០០ នាទីព្រឹក ក្រុមការងារបានជួបជុំអ្នកចូលរួមនៅជិតរង្វង់មូលនាងមច្ឆា អ្នកចូលរួមសរុប ចំនួន ៦០នាក់ មកពីមជ្ឈមណ្ឌលជាតិ

ប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ មន្ទីរសុខាភិបាល នៃរដ្ឋបាលរាជធានីភ្នំពេញ អង្គការដៃគូជាច្រើនដើម្បីរៀបចំបន្តយុទ្ធនាការផ្សព្វផ្សាយអប់រំយល់ដឹងពីមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាមរោគ ក្នុងព្រះរាជពិធីបុណ្យអុំទូកបណ្តែត ប្រទីប និងសំពះព្រះខែ អកអំបុក។




ថ្ងៃនេះផងដែរ ក្រុមការងារបានបែកចែកជាក្រុមតូចៗ ដើម្បីចុះសំណេះសំណាល និងបានធ្វើការអប់រំផ្សព្វផ្សាយស្តីពីមេរោគអេដស៍ ជំងឺអេដស៍ ជំងឺកាមរោគ និងការបង្ការផ្សេងៗ ទៅកាន់បងប្អូនជាកីឡាករអុំទូកដែលកំពុងមានវត្តមាន តាមដងផ្លូវ និងនៅតាមកន្លែងស្នាក់នៅ ដោយមានការសម្របសម្រួលពិសេសជាមួយប្រធានក្រុមរបស់កីឡាករអុំទូកក្នុងការបញ្ជ្រាបការយល់ដឹងស្តីពីការបង្ការមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាមរោគ។ ក្នុងនោះផងដែរថ្នាក់ដឹកនាំ និងក្រុមការងារបានធ្វើបទសម្ភាសន៍ក្រុមសារព័ត៌មាន បានចុះយកព័ត៌មាន និងចុះផ្សាយនូវសកម្មភាព នៃយុទ្ធនាការនេះផងដែល ដើម្បីចូលរួមចំណែកបន្ថែម ក្នុងការពង្រីកការផ្សព្វផ្សាយ ខ្លឹមសារអប់រំនានា នៅក្នុងអំឡុងព្រឹត្តិការណ៍នេះ។



នៅរសៀលថ្ងៃដដែលនេះផងដែរក្រុមការងារបានរៀបចំស្លាយខ្នាតធំ ដើម្បីដាក់បង្ហាញនូវវីដេអូអប់រំផ្សព្វផ្សាយនានាដល់សាធារណជន ជាពិសេសបងប្អូនជាកីឡាករអុំទូកស្នាក់នៅទីនោ ក្រុមការងារបានបន្តចែកខិត្តប័ណ្ណអប់រំសុខភាពស្រោមអនាម័យ សំនួរចម្លើយពីជំងឺអេដស៍និងកាមរោគ ផ្តល់ការប្រឹក្សាធ្វើតេស្តរកមេរោគ អេដស៍-ស្វាយ ដល់អ្នកស្ម័គ្រចិត្តដែលចង់ដឹងពីស្ថានភាពរបស់ខ្លួន។ ក្នុងសកម្មភាពចុះអប់រំផ្សព្វផ្សាយនាពេលនេះ មានការពិតចិត្ត និងចូលរួមយ៉ាងកុះករពីសំណាក់កីឡាករអុំទូក ប្រជាពលរដ្ឋដែលអញ្ជើញចូល



សកម្មភាពអប់រំផ្សព្វផ្សាយ និងធ្វើតេស្តឈាមរកមេរោគអេដស៍ក្នុងព្រឹត្តិការណ៍នៃព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក

រួមក្នុងក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក យ៉ាងច្រើនកុះករ និងទទួលបាន លទ្ធផលជាទីមោទនភាព ក្នុងការចូលរួមបង្ការ ទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាមរោគ ដើម្បីជំរុញឱ្យសម្រេចគោលដៅលុបបំបាត់ការចម្លងមេរោគអេដស៍ថ្មី ស្របតាមគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធី អេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨។

*កម្រងរូបភាពសកម្មភាពថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ ២០២៤*

















## *សមិទ្ធផលសង្ខេបរួម ចាប់ពីថ្ងៃទី១៣ ដល់ ១៥ ខែ វិច្ឆិកា ឆ្នាំ ២០២៤*

| ល.រ | សកម្មភាព | ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០២៤ | ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០២៤ | ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០២៤ | ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០២៤ | **ផ្សេងៗ** |
|---|---|---|---|---|---|---|
| ១ | បានអប់រំផ្សព្វផ្សាយ | 11,479 | 14,700 | 6,480 | | **32,659** |
| ២ | បានធ្វើតេស្តឈាម | 12 *(Female: 5)* | 31 *(Female: 2)* | 27 *(Female: 0)* | | **70** *(Female: 7)* |
| ៣ | លទ្ធផលអេដស៍តេស្ត ប្រតិកម្ម | **00** | **00** | **00** | | **00** |
| ៤ | លទ្ធផលស្វាយតេស្ត ប្រតិកម្ម | **00** | **00** | **00** | | **00** |
| ៥ | បានចែកស្រោមអនាម័យ | 34,419 | 44,322 | 19,728 | | **98,469** |
| ៦ | បានចែកទឹករំអិល | 1,000 | 2,613 | 3,000 | | **6,613** |
| ៧ | បានចែកខិត្តប័ណ្ណ | 11,479 | 8,920 | 2,860 | | **22,259** |
| ៨ | បានចុះឈ្មោះសេវា PrEP | 01 | 00 | 00 | | **01** |
| ៩ | បានចុះឈ្មោះសេវា PEP | 00 | 00 | 02 | | **02** |
| ១០ | អាវយឺតសម្រាប់អប់រំ | 600 | 400 | 100 | | **1,100** |

ថ្ងៃសុក្រ ១៥ កើត ខែកត្តិក ឆ្នាំរោង ឆស័ក ពុទ្ធសករាជ ២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ ២០២៤